ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......១៤១០........អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារ សូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងពីរភេទ ដែលបានប្រឡងជាប់ជាស្ថាពរចូលបំរើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជ្រាបថា :

ផ្អែកតាមលទ្ធផល នៃការប្រឡងជ្រើសរើសមន្ត្រីរាជការ និងសាធារណៈជន ចូលបំរើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម័យប្រឡងថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០១១ មណ្ឌលប្រឡង : សាលាបឋមសិក្សា និងវិទ្យាល័យបាក់ទូក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ចំនួន ៣០០នាក់ ក្នុងនោះរួមមាន : ក្របខ័ណ្ឌ "ក" ៨០នាក់ ក្របខ័ណ្ឌ "ខ" ១០០នាក់ និងក្របខ័ណ្ឌ "គ" ១២០នាក់ ។ អគ្គនាយកដ្ឋានពន្ធដារ នឹងរៀបចំធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ជាទ្រព្យសម្បត្តិរដ្ឋ អគារនៃសាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ និងបើកវគ្គបណ្តុះបណ្តាល ស្តីពីជំនាញពន្ធដារជូនមន្ត្រីរាជការទើបជ្រើសរើសថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលនឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទដូចខាងក្រោម :

- ***កាលបរិច្ឆេទ : ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១***
- ***ពេលវេលា : ម៉ោង ០៦ : ៤៥ នាទីព្រឹក***
- ***ទីកន្លែង : អគារសាលាជាតិពន្ធដារ លេខ ៤៥-៤៧ ផ្លូវលេខ ១១២ ដែលស្ថិតនៅខាងកើត អគារអគ្គនាយកដ្ឋានពន្ធដារ ចម្ងាយ ៧០ម៉ែត្រ***

អាស្រ័យដូចបានជម្រាបជូនខាងលើ អគ្គនាយកដ្ឋានពន្ធដារ សូមអញ្ជើញបេក្ខជនទាំងពីរភេទដែលប្រឡងជាប់ជាស្ថាពរ មកចូលរួមក្នុងពិធីខាងលើនេះកុំបីអាក់ខាន ។

**អគ្គនាយកដ្ឋានពន្ធដារ**

***<u>បញ្ជាក់</u>***

សំលៀកបំពាក់ : ឯកសណ្ឋាននិស្សិត

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700